ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ផែនការគ្រប់គ្រងកន្លែង
# នេសាទសហគមន៍ឃុំកណ្តាល

## រយៈពេល ០៣ ឆ្នាំ

## (ខែមករា ឆ្នាំ ២០១៧ ដល់ខែធ្នូ ឆ្នាំ ២០១៩)

សហគមន៍នេសាទ : តំបន់ឆ្នេរសមុទ្រឃុំកណ្តាល

ភូមិ : កណ្តាល ធ្នង់ ប្រលាន

ឃុំ : កណ្តាល

ស្រុក : បុទុមសាគរ

ខេត្ត : កោះកុង

# មាតិកា


**១-ស្ថានភាពទូទៅ**……………………………………………………………………………៣
**២-អំពីប្រជាសាស្ត្រ**……………………………………………………………………………៣
ក- ប្រជាពលរដ្ឋ……………………………………………………………………………៣
ខ-មុខរបរ……………………………………………………………………………៤
**៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍**……………៤
ក-ទីតាំង……………………………………………………………………………៤
ខ-ដែននេសាទ……………………………………………………………………………៤
គ-តំបន់ដែលមានលទ្ធភាពបង្កើតកន្លែងអភិរក្ស……………………………………………៤
ឃ-ធនធានជលផល……………………………………………………………………………៥
**៤-ការធ្វើនេសាទ**……………………………………………………………………………៥
ក-អ្នកនេសាទ……………………………………………………………………………៥
ខ-ឧបករណ៍នេសាទ……………………………………………………………………………៥
គ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ……………………………………………………៦
**៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ**……………………………………………………………៨
ក-ទស្សនៈវិស័យ……………………………………………………………………………៨
ខ-គោលបំណង……………………………………………………………………………៨
គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍……………………………………………………៨
គ១-ផែនការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ……………………………………៨
គ២-ផែនការប្រើប្រាស់ឧបករណ៍នេសាទ……………………………………………………៨
គ៣-ផែនការស្ថិតិផលនេសាទ និងទូក កាណូត……………………………………………៩
គ៤-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស……………………………………………៩
គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម……………………………………………………………៩
គ៦-ផែនការពង្រឹងសកម្មភាពល្បាត……………………………………………………………១០
គ៧-ផែនការកែច្នៃផលិតផលជលផល និងទីផ្សារ……………………………………………១០
គ.៨.ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ……………………………………………………………១១
គ.៩-ផែនការបង្កើតក្រុមសន្សំប្រាក់……………………………………………………………១១
គ.១០. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ……………………………១១
គ.១១. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ……………………១២
គ.១២.ផែនការថវិកាទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍……………………………………១២
ឃ-យុទ្ធសាស្ត្រ……………………………………………………………………………១៣
-តារាងសង្ខេបផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍រយៈពេល៣ឆ្នាំ ……………………១៦
-តារាងកម្មវិធីការងារ……………………………………………………………………………១៦

# ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តំបន់ឆ្នេរសមុទ្រឃុំកណ្ដោល

## ១-ស្ថានភាពទូទៅ

នៅឆ្នាំ២០០០ រដ្ឋបាលជលផលបានធ្វើកំណែទម្រង់ ដើម្បីឲ្យស្របជាមួយគោលនយោបាយវិមជ្ឈការ-វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលដែលផ្ដោតលើការកាត់បន្ថយភាពក្រីក្រ ដោយផ្ទេរសិទ្ធិអំណាចដល់ប្រជាពលរដ្ឋដែលរស់នៅ ក្នុងតំបន់ជនបទ ដើម្បីចូលរួមគ្រប់គ្រងធនធានជលផលនៅមូលដ្ឋានរបស់ខ្លួនប្រកបដោយចីរភាព និងសមធម៌តាមបែបសហគមន៍នេសាទ ក្នុងគោលបំណងទទួលផលប្រយោជន៍ និងធ្វើឱ្យធនធានជលផលឱ្យប្រសើរឡើងក្នុងមូលដ្ឋានរបស់ខ្លួន។ សហគមន៍នេសាទឃុំកណ្ដោល ត្រូវបានបង្កើតឡើង ឆ្នាំ២០១០ ក្រោមការជួយគាំទ្រថវិកាពីគម្រោងបំរែបំរួលអាកាសធាតុរបស់ក្រសួងបរិស្ថាន និងមានការជួយគាំទ្របច្ចេកទេសពីខណ្ឌរដ្ឋបាលជលផលខេត្តកោះកុងនិងសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

សហគមន៍នេសាទឃុំកណ្ដោលត្រូវបានដឹកនាំដោយគណៈកម្មការ ៧ រូប តាមរយៈការបោះឆ្នោតជ្រើសរើសដោយសមាជិកសហគមន៍នេសាទទាំង ០៣ ភូមិ។ អាណត្តិទី ១ របស់សហគមន៍ មានរយៈពេល ៥ឆ្នាំ ចាប់ពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ២០១០ ដល់ថ្ងៃទី ៣០ ខែធ្នូឆ្នាំ២០១៥ តែជារួមសហគមន៍មិនបានធ្វើមហាសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការថ្មីជំនួសគណៈកម្មការចាស់ដែលផុតអណត្តិឡើយ។ ទោះបីយ៉ាងនេះក្តី គណៈកម្មការសហគមន៍នេសាទបានខិតខំប្រឹងប្រែងធ្វើការងារសំខាន់ៗជាច្រើនដូចជា ការងារទប់ស្កាត់ និងបង្រ្កាបបទល្មើសជលផលដោយបានសហការជាមួយជំនាញជលផល អាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធនានា ហើយបានបន្តដឹកនាំសហគមន៍នេសាទរហូតមកដល់ខែមិថុនា ឆ្នាំ២០១៧ ដោយរង់ចាំការរៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មការអណត្តិថ្មី នៅខែ មិថុនា ឆ្នាំ២០១៧។ ដូចនេះផងដែរ គណៈកម្មការសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្ដោល បានអនុវត្តភារៈកិច្ចរបស់ខ្លួនដែលស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ផែនទីព្រំប្រទល់កន្លែងនេសាទសហគមន៍ និងកិច្ចព្រមព្រៀងកន្លែងនេសាទ។ ទន្ទឹមនឹងនេះ គណៈកម្មសហគមន៍នេសាទត្រូវបានកសាងសមត្ថភាពតាមរយៈការចូលរួមបណ្ដុះបណ្ដាល សិក្ខាសាលា ប្រជុំបណ្ដាញការងារនិងទស្សនកិច្ចសិក្សា និងរៀនសូត្រតាមឯកសារផ្សេងៗ។

## ២-អំពីប្រជាសាស្ត្រ និងសេដ្ឋកិច្ចសង្គម

### ២.១ ស្ថានភាពប្រជាពលរដ្ឋ

ក្នុងឃុំកណ្ដោលមានចំនួន ៥ភូមិ ដែលមានប្រជាពលរដ្ឋសរុប ៩៥៨ គ្រួសារ ស្មើនឹង ៤.១៤៨ នាក់ ស្រី២.០៧១នាក់។ មានភូមិចំនួន៣ បានចូលរួមក្នុងការងារសហគមន៍នេសាទ ដោយមានសមាជិកចំនួន ២៨០ គ្រួសារ ស្មើនឹង ១.២១២ នាក់ (ស្រី ៦០៥ នាក់) ដែលក្នុងនោះភូមិកណ្ដោល ចំនួន ៩៦ គ្រួសារ ភូមិធ្មង់ ចំនួន ១០១ គ្រួសារ និងភូមិប្រលាន ចំនួន ៨៣ គ្រួសារ)។

សមាសភាពប្រជាពលរដ្ឋដែលជាសមាជិកសហគមន៍នេសាទ ក្នុងឃុំកណ្ដោលមាន៖

ក -ប្រជាសាស្ត្រ

| លរ. | សមាសភាព | សរុប | ស្រី |
|---|---|---|---|
| ១ | ស្ត្រីមេម៉ាយក្នុងសហគមន៍នេសាទមាន | ៣១ | ៣១ |
| ២ | ជនពិការក្នុងសហគមន៍នេសាទមាន | ២១ | ៧ |
| ៣ | ចាស់ជរាក្នុងសហគមន៍នេសាទ | ៤០ | ២៧ |
| ៤ | កុមារកំព្រាក្នុងសហគមន៍នេសាទ | ១ | ១ |
| ៥ | អ្នកមានជម្ងឺរ៉ាំរ៉ៃ | ១៨ | ៩ |

<u>កំណត់ចំណាំ:</u>

- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកកាន់សាសនាព្រះពុទ្ធ ៩៩.៦៧ %
- ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទជាអ្នកជនជាតិអីស្លាម ០.៣៣ %

• ក្នុងចំណោមសមាជិកគ្រួសារនៃសមាជិកសហគមន៍នេសាទទាំងអស់អ្នកមិនចេះអក្សរមានចំនួន ៥៨ នាក់ស្រី ២៦ នាក់ ។

ខ-មុខរបរ

មុខរបរសំខាន់ៗរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេះរួមមាន៖

| លរ. | មុខរបរ | គ្រួសារ |
|---|---|---|
| ១ | អ្នកធ្វើនេសាទ | ៤៣ |
| ២ | អ្នកធ្វើស្រែ | ៣៣២ |
| ៣ | អ្នកធ្វើវារីវប្បកម្ម | ១ |
| ៤ | អ្នកដាំបន្លែ | ១៤ |
| ៥ | អ្នកធ្វើចំការ | ៤៦ |
| ៦ | អ្នកចិញ្ចឹមមាន់ | ៣៨៧ |
| ៧ | អ្នកធ្វើជាងផ្ទះ | ១១ |
| ៨ | ជាងជួសជុល | ៥ |
| ៩ | អ្នកលក់ដូរ | ៣០ |
| ១០ | អ្នកកែច្នៃផលនេសាទ | ០ |
| ១១ | អ្នករត់ម៉ូតូឌុប | ២ |
| ១២ | អ្នកធ្វើការងាររោងចក្រ | ៨០ |

## ៣-កន្លែងនេសាទសហគមន៍ និងធនធានដែលមាននៅក្នុងដែននេសាទសហគមន៍

### ក-ទីតាំង

កន្លែងនេសាទសហគមន៍ឃុំកណ្តាលជាដែននេសាទតំបន់ឆ្នេរសមុទ្រមានទំហំ ២.៥៦០ ហិកតា និងមានកំណត់និយាមការដូចមានចែងនៅក្នុងកិច្ចព្រមព្រៀង ។

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្តាល មានព្រំប្រទល់៖

- ខាងជើងទល់នឹងសហគមន៍ការពារធម្មជាតិកណ្តាល
- ខាងត្បូងទល់នឹងសហគមន៍នេសាទឃុំតាមាឃ និងសហគមន៍នេសាទតំបន់ឆ្នេរកោះខ្យង
- ខាងកើតទល់នឹងសហគមន៍នេសាទតំបន់ឆ្នេរកោះខ្យង និង
- ខាងលិចទល់នឹងសហគមន៍នេសាទតំបន់ឆ្នេរឃុំតាមាឃ។

### ខ-ដែននេសាទ:

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្តាល មានកន្លែងមានដូចជា៖

- កន្លែងនេសាទមានទំហំ ២.៤៤៥ ហិកតា
- កន្លែងសម្រាប់អភិវឌ្ឍន៍វារីវប្បកម្ម (ចិញ្ចឹមគ្រែងឈាម) មានទំហំ ៨០ ហិកតា
- កន្លែងកំសាន្តសហគមន៍ មានទំហំ ០៥ហិកតា (ឆ្នេរព្រែកខ្មៅ)

### គ.កន្លែងដែលមានលទ្ធភាពអាចបង្កើតកន្លែងអភិរក្ស

សហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្តាល បានសម្រេចក្នុងការបង្កើតកន្លែងអភិរក្សចំនួន ០៣ កន្លែងគឺកន្លែងចុងក្លងកណ្តាល កន្លែងជាប់ព្រៃកោងកាង កន្លែងបន្តពូជគ្រែងឈាម ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ សត្វកេនិងសត្វស្លាបនិងគ្រែងឈាម។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្តាល ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សត្រីមេពូជទាំងបីមានដូចខាងក្រោម៖

| ល.រ | ប្រភេទកន្លែងអភិរក្ស | ទំហំជា ហត | ការអភិរក្ស |
|---|---|---|---|
| ១ | កន្លែងចុងក្លងកណ្តោល | ១០ | ការអភិរក្សជីវៈចម្រុះទូទៅ |
| ២ | កន្លែងជាប់ព្រៃកោងកាង | ០៥ | ការអភិរក្សសត្វភេ និងសត្វស្លាប |
| ៣ | កន្លែងបន្តពូជគ្រែងឈាម | ២០ | ការអភិរក្សគ្រែងឈាម |
| សរុប | | ៣៥ | |

**ឃ-ធនធានជលផល**

ឃ.១-ប្រភេទត្រីសមុទ្រ:

ក្នុងសហគមន៍នេសាទតំបន់ឆ្នេរសមុទ្រឃុំកណ្តោលមានប្រភេទត្រីដូចជា៖ ត្រីស ត្រីក្អុកក្បាលហៃង ត្រីក្អុកស ត្រីអាំងកើយ ត្រីបេកា ត្រីតុកកែ ត្រីចាប ត្រីអង្រៃ ត្រីកែស ត្រីពួច ត្រីចង្ហមបី ត្រីក្តចិន ត្រីក្បក ត្រីកាម៉ុង ត្រីម្រេច ត្រីស្លង់ ត្រីផ្ទោង ត្រីត្រសក់ ត្រីឆ្លាម ត្រីប្រលូស ត្រីក្អុក ត្រីក្អុក ក្បាលស្រួច ត្រីអាម៉ក់ ត្រីតុកកែ ត្រីបបែល ត្រីអណ្តាតឆ្កែ ត្រីអួយ ត្រីកន្ទុយក្រហម ត្រីអង្រៃ ត្រីកន្ទុយបី ត្រីឆ្មា ត្រីកំពត ត្រីខែ ត្រីគោ ត្រីសមុទ្រទៃ ត្រីប្រកង ត្រីចាបស ត្រីចាបខ្មៅ ត្រីការ៉ាវ ត្រីត្រចៀកដំរី ត្រីដូអង្ករ ត្រីក្រាញ់ ត្រីផ្ទក់ ត្រីអណ្តែង ត្រីបបែល ត្រីប្រម៉ា ត្រីកន្តាំង ត្រីស្លឹកឬស្សី ត្រីអណ្តែងប៉ុយ ត្រីកន្ទុយរឹង ត្រីអណ្តែងខ្លុយ ។ល។

ឃ.២-ប្រភេទវារីសត្វ:

ក្នុងសហគមន៍នេសាទ មានប្រភេទវារីសត្វដូចជា៖បង្គា ក្តាមសេះ ក្តាមថ្ម ក្តាមជ័រ ក្តាមផលិត ក្តាមផ្ករលាន់ អន្ទង់សមុទ្រ មឹក គ្រែងឈាម បង្កងកណ្តូប ខ្យងត្របូន ខ្យងកំបោរ ខ្យងចាក់ច្រែង ខ្យងភ្នែកប្រេីស ខ្យងដែកគោល ខ្យងត្នោត ខ្យងដូង ខ្យងដីរុំ ខ្យងខៀវ (ខ្យងចំពុះទា) ខ្យងផ្លិត ខ្យងចបជីក ខ្យងបន្លា ខ្យងផ្ញើប្រាណ ខ្យងមាត់រៀច ខ្យងតាឱត ងាវភក់ ងាវហូល ងាវស បង្កងប៉ាក អណ្តើកសមុទ្រ កន្ទាយ ប្រទ្បាំងកាស កញ្ជ អន្ទង់ ខ្ទឹង ផ្សោតខ្មៅ ផ្សោតប៉ារ៉ា ល្មិច បង្គ្រប ។ល។

**៤-ការធ្វើនេសាទ**

**ក-អ្នកនេសាទ**

- អ្នកនេសាទជាសមាជិកសហគមន៍ចំនួន ៦៣ នាក់ ស្រី ០១ នាក់
- អ្នកនេសាទមិនមែនជាសមាជិកសហគមន៍នេសាទ នៅក្នុងសហគមន៍ចំនួន ១៩៩ គ្រួសារ
- ប៉ាន់ស្មានអ្នកនេសាទមិនមែនជាសមាជិកដែលមកពីខាងក្រៅសហគមន៍មានចំនួន ២៥០ គ្រួសារ ។

**ខ-ឧបករណ៍នេសាទ**

ឧបករណ៍នេសាទ និងទូកកាណូតរបស់សមាជិកសហគមន៍នេសាទ

| ប្រភេទឧបករណ៍ | ឯកតា | ចំនួន / គ្រួសារ | ទំហំ/ប្រវែង | រដូវប្រើប្រាស់ឧបករណ៍ |
|---|---|---|---|---|
| លបក្តាមថ្ម | លប | ៦៣ | ១០០ លប | ពេញ ១ឆ្នាំ |
| លបបង្កង | លប | ៤ | ៣០ លប | ខែកក្កដា ដល់ខែវិច្ឆិកា |
| មងត្រីក្បក | ម៉ែត្រ | ៦៣ | ២១០ម៉ែត្រ (៣ ដៃ) | ពេញ ១ឆ្នាំ |
| មងក្តាមថ្ម | ម៉ែត្រ | ៥៥ | ៧០០ម៉ែត្រ (១០ ដៃ) | ខែវិច្ឆិកា ដល់ខែមិថុនា |
| មងត្រីកាម៉ុង | ម៉ែត្រ | ៦៣ | ២១០ម៉ែត្រ (៣ ដៃ) | ខែតុលា ដល់ខែមករា |
| មងបង្គា | ម៉ែត្រ | ១៥ | ១៤០ម៉ែត្រ (២ ដៃ) | ខែមេសា ដល់ខែមិថុនា |
| សន្ទូចរនងត្រីក្អុក | ផ្លែ | ២០ | ៣០០ ផ្លែ | ខែឧសភា ដល់ខែសីហា |
| សន្ទូចរនងត្រីអណ្តែងពុយ | ផ្លែ | ២០ | ៣០០ ផ្លែ | ខែឧសភា ដល់ខែសីហា |
| សន្ទូចផ្លែមួយត្រីប៉ាកុង | ផ្លែ | ១១ | | ខែមិថុនា ដល់ ខែសីហា |

| | | | | |
|---|---|---|---|---|
| រើសងាវភុក/ខ្យងភ្នែកប្រើស | | ១៥ | | ពេញ ១ឆ្នាំ |
| ចាប់ក្តាមថ្មដោយដៃ | | ០៣ | | ពេញ ១ឆ្នាំ |
| ចាប់ក្តាមជំរ (ក្តាមខ្មែរ) | | ២៤ | | ពេញ ១ឆ្នាំ |
| ចាប់មឹកដោយដៃ | | ១០ | | ខែវិច្ឆិកា |
| ភរបង្គា | | ១០ | | ខែមេសា |
| ឈិបយន្ត | គ្រឿង | ០៤ | 04 | ពេញ ១ឆ្នាំ |

| ប្រភេទទូក កាណូត | ចំនួន | ចំណុះ | កំលាំងសេះ |
|---|---|---|---|
| ទូកចែវ | ០៩ គ្រឿង | ២០០គីឡូក្រាម | |
| ទូកមានម៉ាស៊ីនបន្ថែត | ៥០ គ្រឿង | ៣០០គីឡូក្រាម ទៅ១.០០០គីឡូក្រាម | ៦-១៨ |
| ទូកមានម៉ាស៊ីនបាត | ០១ គ្រឿង | ១.៥០០គីឡូក្រាម | ៣៥ |

-ឧបករណ៍នេសាទ និងទូកកាណូតរបស់អ្នកនេសាទដែលមកពី ខាងក្រៅ

| ទូក និងប្រភេទឧបករណ៍ | ឯកតា | ចំនួន | ទំហំ/ប្រវែង |
|---|---|---|---|
| ទូកលបក្តាមថ្ម | គ្រឿង | ៣០ | ១ទូក=១៥០-៣០០ លប |
| ទូកលបបង្កង | គ្រឿង | ០៣ | ១ទូក=៤០-៥០លប |
| ទូកមងត្រីក្បក | គ្រឿង | ២៥ | ១ទូក=១០ដៃ/១ដៃ=៧០ម៉ែត្រ |
| ទូកមងក្តាមថ្ម | គ្រឿង | ៣៥ | ១ទូក=២០ដៃ/១ដៃ=៧០ម៉ែត្រ |
| ទូកមងត្រីកាម៉ុង | គ្រឿង | ១៥ | ១ទូក=១០ដៃ/១ដៃ=៧០ម៉ែត្រ |
| ឈិបយន្ត | គ្រឿង | ៣០ | ១ទូក=២០ដៃ/១ដៃ=៧០ម៉ែត្រ |

-អ្នកនេសាទដោយដៃដែលមកពី ខាងក្រៅ

| ប្រភេទផលនេសាទ | ឯកតា | ចំនួនសរុប |
|---|---|---|
| ចាប់ក្តាមជំរ (ក្តាមខ្មែរ) | គ្រួសារ | ៧ |
| ចាប់មឹកដោយដៃ | គ្រួសារ | ២ |

## ឆ-ការប៉ាន់ប្រមាណផលចាប់បានប្រចាំឆ្នាំ

| ប្រភេទផលនេសាទ | បរិមាណផលនេសាទចាប់បានគិតជាមធ្យមប្រចាំគ្រួសារ(គិតជាគីឡូក្រាម) | | |
|---|---|---|---|
| | រដូវប្រាំង | រដូវវស្សា | សរុបប្រចាំឆ្នាំ |
| លបក្តាមថ្ម | ពេញ ១ ឆ្នាំ<br>១ខែ = ១៤ ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ៥៦.៩៥២គីឡូក្រាម |
| លបបង្កង | | ខែកក្កដា ដល់ ខែវិច្ឆិកា<br>១ខែ=១៥ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ២.០២៥គីឡូក្រាម |
| មងត្រីក្បក | ពេញ ១ឆ្នាំ<br>១ខែ=១២ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ៧៧.៩៧០គីឡូក្រាម |

| | | | |
|---|---|---|---|
| មងក្ដាមថ្ម | ខែវិច្ឆិកា ដល់ ខែមិថុនា<br>១ខែ=១៥ ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ៤០.៨០០គីឡូក្រាម |
| មងត្រីកាម៉ុង | | ខែតុលា ដល់ ខែមករា<br>១ខែ=១០ ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ២៣.៦៤០គីឡូក្រាម |
| មងបង្គា | | ខែមេសា ដល់ ខែមិថុនា<br>១ខែ=៧ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ៩៤៥គីឡូក្រាម |
| សន្ទូងរនងត្រីក្អក | | ខែឧសភា ដល់ ខែសីហា<br>១ខែ=១០ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ៤.០០០ គីឡូក្រាម |
| សន្ទូងរនងត្រីអណ្ដែងពុយ | | ខែឧសភា ដល់ ខែសីហា<br>១ខែ=១០ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ១.៦០០គីឡូក្រាម |
| សន្ទូចផ្លែមួយត្រីប៉ាកុង | | ខែមិថុនា ដល់ ខែសីហា<br>១ខែ=១០ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | ៦៦០គីឡូក្រាម |
| រើសងាវកុក/ខ្យងភ្នែកប្រើស | ពេញ ១ឆ្នាំ<br>១ខែ=១១ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ២៩.៧០០គីឡូក្រាម |
| ចាប់ក្ដាមថ្មដោយដៃ | ពេញ ១ឆ្នាំ<br>១ខែ=៨ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ៦១២ គីឡូក្រាម |
| ចាប់ក្ដាមជ័រ (ក្ដាមខ្មៅ) | ពេញ ១ឆ្នាំ<br>១ខែ=៨ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ១០.៩១៤គីឡូក្រាម |
| ចាប់មឹកដោយដៃ | ខែវិច្ឆិកា<br>១ខែ=៧ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ២១០គីឡូក្រាម |
| រាវបង្គា | ខែមេសា<br>១ខែ=០៥ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ៥០គីឡូក្រាម |
| មីងប៉ាកាំង | ខែមករា ដល់ ខែមេសា<br>១ខែ=១៨ថ្ងៃ<br>១ថ្ងៃ=គីឡូក្រាម | | ១.៨០០គីឡូក្រាម |
| ប្រភេទត្រីជី | ពេញ ១ឆ្នាំ<br>១ខែ=១៥ថ្ងៃ | | ១៧៤.៥៩១ គីឡូក្រាម |

| | ១ថ្ងៃ=គីឡូក្រាម | | |
|---|---|---|---|

## ៥-ផែនការគ្រប់គ្រងសហគមន៍នេសាទ

### ក-ទស្សនៈវិស័យ

សហគមន៍នេសាទឃុំកណ្តាល មានទស្សនៈវិស័យរួមចំណែកគ្រប់គ្រងធនធានជលផលប្រកបដោយសមធម៌ និងចីរភាព ដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

### ខ-គោលបំណង

- ចូលរួមគ្រប់គ្រងដែននេសាទ កន្លែងនេសាទគ្រួសារដែល រក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណី ឬ សហគមន៍ធ្វើនេសាទ កន្លែងនេសាទបំរុង និងកន្លែងនេសាទតាមឆ្នេរ។
- ចូលរួមគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តភាព និងធានាការបែងចែកផលប្រយោជន៍ធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌។
- ដើម្បីធ្វើឱ្យប្រសើរឡើងនូវជីវភាពសមាជិកសហគមន៍ តាមរយៈការអភិវឌ្ឍន៍ចំរុះដោយមានការចូលរួម។
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ច្បាស់ ហើយនឹងឈានទៅចាត់ទុកថាខ្លួនជាម្ចាស់លើធនធានធម្មជាតិ។

### គ-ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

#### គ.១-ផែនការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ

ដោយសហគមន៍នេសាទឃុំកណ្តាលត្រូវដល់អាណត្តិ ផែនការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ គឺនឹងត្រូវបានរៀបចំឡើងវិញ ដើម្បីស្របទៅនឹងលក្ខន្តិកៈសហគមន៍នេសាទ។

ផែនការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| កំណត់បេក្ខជនឈរឈ្មោះគណៈកម្មការសហគមន៍នេសាទ | ០១/០៦/២០១៧ | ៣០/០៦/២០១៧ |
| រៀបចំសន្និបាតបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ | ០១/០៦/២០១៧ | ៣០/០៦/២០១៧ |
| ពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ | ២០១៧ | ២០១៩ |

#### គ.២-ផែនការប្រើប្រាស់ឧបករណ៍នេសាទ

ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទសហគមន៍គឺ រៀបចំឡើងដោយបានគិតគូរអំពីប្រភេទដែននេសាទ ប្រភេទទំហំ ប្រវែងចំនួនឧបករណ៍នេសាទចំនួនអ្នកនេសាទ និងរដូវនេសាទ និងការប៉ាន់ប្រមាណផលស្តុកដែលមាននៅក្នុងកន្លែងនេសាទ ដោយដោយធ្វើយ៉ាងណាមិនឱ្យការធ្វើនេសាទលើសពីតម្រូវការធនធានជលផលដែលមានក្នុងកន្លែងសហគមន៍នេសាទ។ ផែនការប្រើប្រាស់ឧបករណ៍នេសាទនៅក្នុងកន្លែងនេសាទត្រូវបានរៀបចំឡើងដូចខាងក្រោមៈ

| ឈ្មោះ/ទីតាំងកន្លែងនេសាទ | ពេលវេលាធ្វើនេសាទ | ឧបករណ៍នេសាទអនុញ្ញាតឱ្យប្រើ | | | ផ្សេងៗ |
|---|---|---|---|---|---|
| | | ប្រភេទ | ទំហំ/ប្រវែង | ចំនួន | |
| ដែននេសាទ តំបន់ឆ្នេរសមុទ្រឃុំកណ្តាល | ពេញ ១ឆ្នាំ | លបក្តាមថ្ម | ៣០០ លប | ៩៣ គ្រួសារ | |
| | ខែ កក្កដា ដល់ខែ វិច្ឆិកា | លបបង្កង | ៥០ លប | ៧ គ្រួសារ | |
| | ពេញ ១ ឆ្នាំ | មងត្រីក្បក | ១៥០០ ម៉ែត្រ | ៨៨ គ្រួសារ | |
| | ខែ វិច្ឆិកា ដល់ខែ មិថុនា | មងក្តាមថ្ម | ១៥០០ ម៉ែត្រ | ៩០ គ្រួសារ | |
| | ខែ តុលា ដល់ខែ មករា | មងត្រីកាម៉ុង | ១៥០០ ម៉ែត្រ | ៧៨ គ្រួសារ | |
| | ខែ មេសា ដល់ខែ មិថុនា | មងបង្គា | ១៥០០ ម៉ែត្រ | ១៥ គ្រួសារ | |
| | ខែ ឧសភាដល់ខែ សីហា | សន្ទូចរនងត្រីក្អុក | ៣០០ ផ្លែ | ២០ គ្រួសារ | |

| | | | | | |
|---|---|---|---|---|---|
| | ខែឧសភា ដល់ខែ សីហា | សន្ទូចរនងត្រីអណ្តែងពុយ | ៣០០ ផ្លែ | ២០ គ្រួសារ | |
| | ខែ មិថុនា ដល់ខែ សីហា | សន្ទូចផ្លែមួយត្រីប៉ាកុង | | ១១ គ្រួសារ | |
| | ខែ មករា ដល់ខែ មេសា | ម៉ងប៉ាកាំង | ១៥០០ ម៉ែត្រ | ៥ គ្រួសារ | |

**គ.៣-ផែនការស្ថិតិផលនេសាទ និងទូក កាណូត**

ផែនការស្ថិតិផលនេសាទ និងទូក កាណូត នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ប្រជុំរៀបចំបង្កើតក្រុមការងារ | ២៧/០២/២០១៧ | ០១/០៣/២០១៧ |
| បណ្តុះបណ្តាលក្រុមការងារអំពី នីតិវិធីនៃការប្រមូលព័ត៌មាន | ២៧/០២/២០១៧ | ០១/០៣/២០១៧ |
| បែងចែកតួនាទី ភារកិច្ចក្រុមការងារ | ២៧/០២/២០១៧ | ០១/០៣/២០១៧ |
| ផ្សព្វផ្សាយដល់ប្រជានេសាទ | ០១/០៤/២០១៧ | ៣០/០៤/២០១៧ |
| ចុះស្រង់ស្ថិតិ | ០១/០៤/២០១៧ | ៣០/០៤/២០១៧ |
| ចងក្រងទិន្នន័យ | ០១/០៤/២០១៧ | ៣០/០៤/២០១៧ |

**គ.៤-ផែនការកំណត់ និងរៀបចំកន្លែងអភិរក្ស**

សហគមន៍នេសាទឃុំកណ្តោល បានសម្រេចបង្កើតកន្លែងអភិរក្សចំនួន ០១កន្លែង គឺចុងក្លងកណ្តោល ដែលជាកន្លែងមានសក្តានុពលសម្រាប់អភិរក្សត្រីមេពូជ ត្រី ក្តាម និងបង្គា ។ ដូចនេះផងដែរ កន្លែងអភិរក្សបានធ្វើការគ្រប់គ្រងបន្ទាប់ពីសហគមន៍នេសាទឃុំកណ្តោល ត្រូវបានប្រកាសទទួលស្គាល់ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយកន្លែងអភិរក្សនេះបង្កើតឡើងក្នុងគោលបំណង៖

- បង្កើនពូជត្រី និងវារីសត្វគ្រប់ប្រភេទ
- ជាជម្រកនិងប្រភពចំណីរបស់ត្រីនិងសត្វ
- ផ្តល់ចំណេះដឹងដល់ប្រជាពលរដ្ឋ ឱ្យចេះស្រឡាញ់ថែរក្សា ការពារធនធានធម្មជាតិ និង
- ពិសេស ធនធានជលផល បរិស្ថាន និងចូលរួមលុបបំបាត់ការនេសាទខុសច្បាប់។

តាមការចុះអង្កេត ការពិនិត្យនិងពិភាក្សាលើលក្ខណៈវិនិច្ឆ័យជាមួយគណៈកម្មការនិងសមាជិកសហគមន៍នសាទនេះបានបញ្ជាក់ថា សហគមន៍នេសាទឃុំកណ្តោល បានសម្រេចបង្កើតកន្លែងអភិរក្សយ៉ាងតឹងរឹងដែលមានទំហំ ១០ ហិកតា ដោយមានសុច្ឆន្ទៈចង់ចូលរួមក្នុងការគ្រប់គ្រងធនធានជលផល ដើម្បីធានានូវប្រសិទ្ធភាពនៃការគ្រប់គ្រងធនធានជលផលនិងជាប្រយោជន៍សម្រាប់តម្រូវការផលត្រីរបស់ប្រជាពលរដ្ឋក្នុងសហគមន៍។ ដូចនេះការកំណត់ និងរៀបចំកន្លែងអភិរក្ស នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ឈ្មោះដែននេសាទ | ទំហំ(ហិកតា) | ប្រភេទនៃការអភិរក្ស | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|---|
| ចុងក្លងកណ្តោល | ១០ | ត្រី ក្តាម បង្គា បង្កង | • ប្រជុំរៀបចំផែនការ<br>• ចុះពិនិត្យមើលទីតាំង<br>• ផ្សព្វផ្សាយ<br>• ដាក់ស្លាកសញ្ញា និង បោះបង្គោល<br>• ការងារល្បាត | ២០១៧ | ២០១៩ |

**គ៥-ផែនការអភិវឌ្ឍន៍វារីវប្បកម្ម**

ការអភិវឌ្ឍន៍វារីវប្បកម្មរបស់សហគមន៍នេសាទពាមក្រសោបក្នុងគោលបំណង៖

- បង្កើនត្រីសាច់សម្រាប់ហូបចុក របស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន
- បង្កើនប្រាក់ចំណូលដែលជួយស្ទួយសេដ្ឋកិច្ចគ្រួសារ
- កាត់បន្ថយសម្ពាធអាជីវកម្មលើធនធានជលផលហួសកំរិត។

ឆ្លើយតបនឹងទៅនឹងការពង្រីកការអភិវឌ្ឍន៍វារីវប្បកម្ម គណៈកម្មការ និងសមាជិកសហគមន៍នេសាទបានរៀបចំផែនការអភិវឌ្ឍន៍វារីវប្បកម្ម នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| ប្រភេទ | ចំនួន(ស្រះ) | ប្រភេទកូនត្រីពូជ | បរិមាណកូនត្រីពូជ | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|---|---|---|
| ការចិញ្ចឹមត្រីក្នុងស្រះ | ៥ | អណ្តែង, ទីឡាព្យា, ឆ្ពិន | ៧៥០០ | ២០១៧ | ២០១៩ |
| ការចិញ្ចឹមក្នុងថង់ប្លាស្ទិក | ៨ | អណ្តែង | ៤០០០ | ២០១៧ | ២០១៩ |

**គ.៦-ផែនការពង្រឹងសកម្មភាពល្បាត**

ដើម្បីគ្រប់គ្រង ថែរក្សា ការពារ អភិរក្សធនធានធម្មជាតិ ជាពិសេសធនធានជលផលឲ្យមានភាពល្អប្រសើរ និងមាននិរន្តរភាព សហគមន៍នេសាទមានផែនការពង្រឹងការចុះល្បាតនៅក្នុងកន្លែងនេសាទសហគមន៍ឲ្យបានជាប្រចាំ ។
ផែនការសម្រាប់ពង្រឹងការងារចុះល្បាតឲ្យមានប្រសិទ្ធភាព នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| រៀបចំក្រុមល្បាត | ២០១៧ | ២០១៩ |
| រៀបចំបែងចែកតួនាទី និងភារកិច្ចទទួលខុសត្រូវ | ២០១៧ | ២០១៩ |
| បណ្តុះបណ្តាលអំពី នីតិវិធីក្នុងការបង្ក្រាបបទល្មើស | ២០១៧ | ២០១៩ |
| រៀបចំតារាងពេលវេលាចុះល្បាត | ២០១៧ | ២០១៩ |
| ចុះល្បាត | ២០១៧ | ២០១៩ |

**គ.៧-ផែនការកែច្នៃផលិតផលជលផល និង ទីផ្សារ**

ការកែច្នៃផលិតផលជលផល គឺផ្នែកមួយដែលអាចជួយធ្វើឱ្យផលិតផលជលផលរបស់សមាជិកសហគមន៍នេសាទ ចូលដល់ទីផ្សារក្នុងតំបន់ ដើម្បីជួយបង្កើនមុខរបរបន្ថែមដល់ប្រជានេសាទនៅក្នុងសហគមន៍នេះ។ កន្លងមក អង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសធ្វើការកែច្នៃផលិតផលជលផលតាមលក្ខណៈគ្រួសារ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិង បង្កើនប្រាក់ចំណូល
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

គណៈកម្មការសមាជិកសហគមន៍នេសាទឃុំកណ្តោល បានរៀបចំផែនការសម្រាប់ការកែច្នៃផលិតផលជលផលដូចមានក្នុងតារាងខាងក្រោម៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| បង្កើតក្រុមកែច្នៃសហគមន៍នេសាទ | ២០១៧ | ២០១៩ |
| ផ្តល់ជំនាញកែច្នៃត្រី-បង្គា -កាពិ-ងាវភក់ | ២០១៧ | ២០១៩ |
| ជំនាញទីផ្សារ | ២០១៧ | ២០១៩ |
| ជំនាញវេចខ្ចប់ផលិតផល | ២០១៧ | ២០១៩ |
| បណ្តុះបណ្តាលក្រុមផលិត | ២០១៧ | ២០១៩ |

គ.៨.ផែនការអភិវឌ្ឍន៍កម្មវិធីចំរុះ

ការគាំទ្រមុខរបរចិញ្ចឹមជីវិតដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទ នៅងក្នុងសហគមន៍នេះ ។ កន្លងមក អង្គការដៃគូអភិវឌ្ឍន៍បានជួយបណ្តុះបណ្តាលអំពីបច្ចេកទេសការចិញ្ចឹមសត្វ ព្រមទាំងការចិញ្ចឹមជីវិតផ្សេងៗទៀតដល់សមាជិកសហគមន៍នេសាទ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរបង្កើនប្រាក់ចំណូល
- ជួយកាត់បន្ថយអត្រាចំណាកស្រុក
- ផ្តល់ចំណេះដឹងជំនាញនិងបច្ចេកទេស (ចិញ្ចឹមសត្វ កសិកម្មសមស្រប)

ការពង្រីក និងបន្ថែមមុខរបរចិញ្ចឹមជីវិត នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| ចិញ្ចឹមមាន់ | ២០១៧ | ២០១៩ |
| ដាំបន្លែ | ២០១៧ | ២០១៩ |
| បណ្តុះផ្សិត | ២០១៧ | ២០១៩ |

គ.៩-ផែនការបង្កើតក្រុមសន្សំប្រាក់

ការគាំទ្រមុខរបរចិញ្ចឹមជីវិតបន្ថែមដល់សមាជិកសហគមន៍នេសាទ ជាសកម្មភាពចំបងដែលជួយពង្រីកមុខរបរដល់ប្រជានេសាទ នៅងក្នុងសហគមន៍នេះ ដើម្បីរួមចំណែកជួយលើកស្ទួយសេដ្ឋកិច្ចគ្រួសារក្នុងគោលបំណង៖

- ដើម្បីឱ្យប្រជាពលរដ្ឋមានមុខរបរនិងមានដើមទុនសំរាប់បង្កើនប្រាក់ចំណូល
- កាត់បន្ថយអត្រាការប្រាក់ខ្ពស់និងខ្ចីប្រាក់ពីឈ្មួញ
- ដើម្បីឱ្យសហគមន៍មានដើមទុនសម្រាប់អនុវត្តការងារដោយខ្លួនឯង

ផែនការបង្កើតក្រុមសន្សំប្រាក់ នឹងត្រូវបានរៀបចំឡើងដូចខាងក្រោម ៖

| សកម្មភាព | ថ្ងៃ ខែ ឆ្នាំ ចាប់ផ្តើម | ថ្ងៃ ខែ ឆ្នាំ បញ្ចប់ |
|---|---|---|
| បង្កើតក្រុមសន្សំប្រាក់ | ២០១៧ | ២០១៩ |
| បណ្តុះបណ្តាលក្រុមសន្សំប្រាក់ | ២០១៧ | ២០១៩ |

គ.១០. ផែនការពង្រឹងសមត្ថភាពគណៈកម្មការសហគមន៍នេសាទ

ជាទូទៅ បេក្ខជនដែលឈរឈ្មោះជាគណៈកម្មការសហគមន៍នេសាទគួរត្រូវបានបញ្ជាក់ពីគុណភាព និងចំណេះដឹងដូចជា៖ ចេះអាន សរសេរ អាកប្បកិរិយាសមរម្យ ដោយឯកភាពពីសមាជិកសហគមន៍ ហើយការរៀបចំបោះឆ្នោតជ្រើសរើសជាគណៈកម្មការបានប្រើនីតិវិធីដែលស្របតាមគោលការណ៍ណែនាំសហគមន៍នេសាទ ដែលបានអនុម័តដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។ ជាក់ស្តែង គណៈកម្មការសហគមន៍នេសាទនេះ ត្រូវបានជ្រើសរើសតាមរយៈការបោះឆ្នោតដោយត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រច្រើនជាងគេ ហើយជាញឹកញាប់សមាសភាពគណៈកម្មការសហគមន៍នេសាទ មានកំរិតលើការយល់ដឹងពីលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ជំនាញសម្របសម្រួល ទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍន៍ និងការៀបផែនការគ្រប់គ្រងកន្លែង សហគមន៍នេសាទ។ ដូចនេះ ផែនការបណ្តុះបណ្តាលដល់សមាសភាពគណៈកម្មការសហគមន៍នេសាទ នឹងត្រូវបានរៀបចំក្នុងគោលបំណង៖

- យល់ពីតួនាទីនិងភារកិច្ចរបស់ពួកគាត់ និង
- បង្កើនសាមគ្គីភាពនិងការទំនាក់ទំនងល្អជាមួយសហគមន៍ និងអ្នកពាក់ព័ន្ធ

- គណៈកម្មការសហគមន៍នេសាទនឹងអាចអនុវត្តសកម្មភាពក្នុងការងារ។

| លរ | សកម្មភាព | ចំនួន | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ |
|---|---|---|---|---|
| ១ | បណ្តុះបណ្តាលរបៀបធ្វើកំណត់ហេតុ សរសេរលិខិត រដ្ឋបាលរបាយការណ៍ និងរៀបចំទុកឯកសារ | ១លើក | ២០១៧ | ២០១៧ |
| ២ | បណ្តុះបណ្តាលការគ្រប់គ្រងថវិកា | ១លើក | ២០១៨ | ២០១៨ |
| ៣ | បណ្តុះបណ្តាលការដោះស្រាយទំនាស់ | ១លើក | ២០១៨ | ២០១៨ |
| ៤ | បណ្តុះបណ្តាលជំនាញក្នុងការសម្របសម្រួល | ១លើក | ២០១៩ | ២០១៩ |
| ៥ | បណ្តុះបណ្តាលការរៀបចំផែនការ | ១លើក | ២០១៩ | ២០១៩ |

### គ.១១. ផែនការផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ

ពេលបច្ចុប្បន្ន ធនធានជលផលក្នុងសហគមន៍កំពុងទទួលរងនូវការគំរាមកំហែងពីអ្នកខាងក្នុងនិងខាងក្រៅ លើធនធានជលផលដោយប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ ដូចនេះ ដើម្បីធានាការប្រើប្រាស់ធនធានជលផលពេលអនាគត និងបានយូរអង្វែងនោះ តម្រូវធ្វើការផ្សព្វផ្សាយអំពីច្បាប់ស្តីពី ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធឲ្យបានទូលំទូលាយដល់ប្រជាពលរដ្ឋនៅមូលដ្ឋាន ដើម្បីឲ្យមានការយល់ដឹងគ្រប់គ្រាន់ និងចូលរួមចំណែកក្នុងការគ្រប់គ្រង និងប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាព ។ ការផ្សព្វផ្សាយអំពីច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធក្នុងគោលបំណង៖

- បង្កើនការយល់ដឹងដល់ប្រជាពលរដ្ឋក្នុងសហគមន៍
- កាត់បន្ថយសកម្មភាពបទល្មើសនេសាទក្នុងសហគមន៍

ផែនការសកម្មភាពមានដូចខាងក្រោម៖

| ឈ្មោះសកម្មភាព | អ្នកទទួលខុសត្រូវ | រយៈពេលអនុវត្ត(៣ឆ្នាំ) | | | តម្លៃប៉ាន់ស្មាន (គិតជារៀល ) | ប្រភពទុន |
|---|---|---|---|---|---|---|
| | | ទី១ | ទី២ | ទី៣ | | |
| ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ | ខណ្ឌរដ្ឋបាលជលផល | ៤ | ៤ | ៤ | ៦០០.០០០ | ថវិកាឃុំកម្មវិធី EU |
| ផ្សព្វផ្សាយលក្ខន្តិកៈនិងបទបញ្ជាផ្ទៃ | គណៈកម្មការ | ៤ | ៤ | ៤ | ៦០០.០០០ | ថវិកាឃុំដៃគូអភិវឌ្ឍ |

### គ.១២.ផែនការថវិការទ្រទ្រង់សម្រាប់អភិវឌ្ឍន៍សហគមន៍

ដោយឡែក គណៈកម្មការសហគមន៍បានដើរតួនាទសំខាន់ក្នុងការស្វែងរកប្រាក់ចំណូលនិងចំណាយពីប្រភពផ្សេងៗដូចជា៖ ភាគទានពីសមាជិកសហគមន៍ អង្គការដៃគូអភិវឌ្ឍន៍ សប្បុរសជន និងចំណូលពីក្រុមសន្សំប្រាក់ ។

ដូចនេះផែនការស្វែងរកថវិការសម្រាប់ទ្រង់សហគមន៍មានក្នុងតារាងខាងក្រោម៖

| ប្រភេទប្រាក់ចំណូល | សកម្មភាព | ថ្ងៃខែឆ្នាំចាប់ផ្តើម | ថ្ងៃខែឆ្នាំបញ្ចប់ | ចំណូលសរុប (រៀល) |
|---|---|---|---|---|
| ភាគទានពីសមាជិកសហគមន៍ | ចុះប្រមូលប្រាក់សមាជិកភាព | ២០១៧ | ២០១៩ | ១.២០០.០០០ |

| | | | | |
|---|---|---|---|---|
| ភាគទានប្រចាំឆ្នាំ | ចុះប្រមូលប្រាក់ភាគទានប្រចាំឆ្នាំ | ២០១៧ | ២០១៩ | ៨០០.០០០ |
| ភាគទានពីអ្នកខាងក្រៅ ឬអ្នកមិនមែនជាសមាជិក | ប្រមូលប្រាក់បដិភាគពីអ្នកនេសាទខាងក្រៅ | ២០១៧ | ២០១៩ | ១.២៥០.០០០ |
| ភាគទានពីក្រុមសន្សំ | ប្រាក់បដិភាគពីក្រុមសន្សំ | ២០១៧ | ២០១៩ | ១.០០០.០០០ |
| សារសេរគម្រោងស្នើសុំៈ -អង្គការដៃគូ | -គម្រោងស្នើសុំពីអង្គការ | ២០១៧ | ២០១៩ | ១.០០០.០០០ |

ឃ-យុទ្ធសាស្ត្រ

ដើម្បីអនុវត្តផែនការឱ្យទទួលបានជោគជ័យ យុទ្ធសាស្ត្រមួយចំនួនត្រូវបានរៀបចំ ដូចខាងក្រោម :

- បង្កើតគណៈកម្មការសម្រាប់អនុវត្តតាមដានត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការរួមមាន សមាជិក គណៈកម្មការសហគមន៍នេសាទ ចាស់ទុំដែលមានបទពិសោធន៍ និងចំណេះដឹងល្អៗជាពិសេសបញ្ហានេសាទ។
- ស្នើសុំជំនួញបច្ចេកទេសពីរដ្ឋបាលជលផលមានសមត្ថកិច្ច ដើម្បីជួយផ្តល់យោបល់ចំពោះផែនការណាដែលទាក់ទងនិងបច្ចេកទេសជលផលដូចជា ការធ្វើផែនការកន្លែងអភិរក្សមេពូជត្រី ការរៀបចំកន្លែងអភិរក្សព្រៃលិចទឹក កន្លែងអភិរក្សជីវៈចម្រុះ ការកំណត់ឧបករណ៍នេសាទ ការចិញ្ចឹមត្រី ការរកថវិកាទ្រទ្រង់ជាដើម ។
- រៀបចំយុទ្ធសាស្ត្រទំនាក់ទំនងជាមួយស្ថាប័នជំនាញ អង្គការនានា គម្រោងនិងម្ចាស់ជំនួយដើម្បីទទួលបានការ ឧបត្ថម្ភគាំទ្រ និងថវិការសម្រាប់ដំណើរការអនុវត្តផែនការ។
- រៀបចំផែនការអនុវត្តផែនការតាមដំណាក់កាលនិមួយៗដោយជាក់លាក់។
- ទាក់ទងជាមួយរដ្ឋបាលជលផលដើម្បីសុំការគាំទ្រថវិការ និងជួយរកដៃគូសម្រាប់ទ្រទ្រង់ផែនការគ្រប់គ្រងសហគមន៍។
- ផ្សព្វផ្សាយផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ដល់សមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីជម្រុញការចូលរួម និងគាំទ្រដល់ការអនុវត្តផែនការគ្រប់គ្រងនេះ។
- កៀងគរការចូលរួមចំណែករបស់សមាជិកសហគមន៍នេសាទ។
- រៀបចំវិធានការណ៍ចំពោះអ្នកនេសាទមកពីខាងក្រៅសហគមន៍។
- ពង្រឹងសម្ថភាពបច្ចេកទេស និង គ្រប់គ្រងរបស់គណៈកម្មការសហគមន៍នេសាទ។
- ចងក្រងក្រុមអ្នកនេសាទទៅតាមប្រភេទឧបករណ៍នេសាទ ដើម្បីចូលរួមអនុវត្តផែនការ។
- បញ្ចូលផែនការគ្រប់គ្រងសហគមន៍នេសាទទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។

## ការាងសង្ខេបផែនការគ្រប់គ្រងតំបន់ការពារធនធានជលផលសហគមន៍នេសាទរយៈពេល ៣ឆ្នាំ (២០១៧ ដល់ ២០១៩)

| ប្រភេទផែនការ/សកម្មភាព | លទ្ធផលរំពឹងទុក | ការប៉ាន់ស្មានចំណាយ (រៀល) | ប្រភពជំនួយ | ពេលផ្តើម | ពេលបញ្ចប់ |
|---|---|---|---|---|---|
| ១.ការងារគ្រប់គ្រងធនធានជលផល | | | | | |
| ១.១.ចុះស្ថិតិឧបករណ៍នេសាទនិងទូកនេសាទ | ស្ថិតិឧបករណ៍នេសាទនិងទូកនេសាទ ត្រូវបានធ្វើ | ១,៥00,000 | ដៃគូអភិវឌ្ឍ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ១.២.រៀបចំផែនការល្បាតទប់ស្កាត់បទល្មើស | ផែនការល្បាតទប់ស្កាត់បទល្មើស ត្រូវបានរៀបចំ | ១,៥00,000 | | ២០១៧ | ២០១៩ |
| ១.៣.បោះបង្គោលព្រំប្រទល់សហគមន៍នេសាទ | បង្គោលព្រំប្រទល់សហគមន៍នេសាទ ត្រូវបានបោះ | ១២,000,000 | | ២០១៧ | ២០១៩ |
| ២.ផែនការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សមាជិកនិងអ្នកខាងក្រៅ | | | | | |
| ២.១.ផែនទីកន្លែងនេសាទសហគមន៍កណ្តាល | ផែនទីកន្លែងនេសាទសហគមន៍កណ្តាល ត្រូវបានរៀបចំ | ១,២00,000 | ដៃគូអភិវឌ្ឍ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ២.២.ធនធានជលផលក្នុងកន្លែងសហគមន៍នេសាទ | ធនធានជលផលក្នុងកន្លែងសហគមន៍នេសាទត្រូវបានគ្រប់គ្រង | ១,២00,000 | | ២០១៧ | ២០១៩ |
| ២.៣.ធ្វើបច្ចុប្បន្នភាពលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុង | បច្ចុប្បន្នភាពលក្ខន្តិកៈនិងបទបញ្ជាផ្ទៃក្នុងត្រូវបានរៀបចំ | ១,២00,000 | | ២០១៧ | ២០១៩ |
| ២.៤.ផ្សព្វផ្សាយពីច្បាប់ជលផល និងលិខិតបទដ្ឋានដែលពាក់ព័ន្ធ | ច្បាប់ជលផល និងលិខិតបទដ្ឋានពាក់ព័ន្ធ ត្រូវបានផ្សព្វផ្សាយ | ១,២00,000 | | ២០១៧ | ២០១៩ |
| **២.៥.ផ្សព្វផ្សាយពីសុវត្ថិភាពលើផ្ទៃសមុទ្រ** | **សុវត្ថិភាពលើផ្ទៃសមុទ្រ ត្រូវបានផ្សព្វផ្សាយ** | ១,២00,000 | | **២០១៧** | **២០១៩** |
| ៣.ការអភិវឌ្ឍន៍ធនធានមនុស្សក្នុងសហគមន៍នេសាទ | | | | | |
| *៣.១.ផែនការកសាងធនធានមនុស្សលើការការងារគ្រប់គ្រង និងអភិវឌ្ឍ* | | | | ២០១៧ | ២០១៩ |
| ៣.១.១.ការងាររដ្ឋបាល និងគ្រប់គ្រងបញ្ជីស្នាម (សរសេររបាយការណ៍ សរសេរកំណត់ហេតុ និងហិរញ្ញវត្ថុ) | សរសេររបាយការណ៍ សរសេរកំណត់ហេតុ និងហិរញ្ញវត្ថុ ត្រូវបានបណ្តុះបណ្តាល | ១,៦00,000 | ដៃគូអភិវឌ្ឍ<br>សប្បុរសជន<br>រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៣.១.២.ផែនការសរសេរគម្រោងស្នើសុំថវិកា | ការសរសេរគម្រោងស្នើសុំថវិកា ត្រូវបានបណ្តុះបណ្តាល | ១,៦00,000 | | ២០១៧ | ២០១៩ |
| ៣.១.៣. បណ្តុះបណ្តាលពីភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ | ភាពជាអ្នកដឹកនាំ និងអភិបាលកិច្ចល្អ ត្រូវបានបណ្តុះបណ្តាល | ១,៦00,000 | | ២០១៧ | ២០១៩ |
| ៣.១.៤. ជំនាញសម្របសម្រួលនិងដោះស្រាយទំនាស់ | ជំនាញសម្របសម្រួលនិងដោះស្រាយទំនាស់ ត្រូវបានបណ្តុះបណ្តាល | ១,៦00,000 | | ២០១៧ | ២០១៩ |
| ៣.១.៥.បណ្តុះបណ្តាលពីការគ្រប់គ្រងទូកនេសាទ និងសុវត្ថិភាពលើផ្ទៃសមុទ្រ | ការគ្រប់គ្រងទូកនេសាទ បានបណ្តុះបណ្តាល | ១,៦00,000 | | ២០១៧ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| ៣.១.១.បណ្តុះបណ្តាលពីការប្រមូល និងកត់ត្រាផលចាប់ | បណ្តុះបណ្តាលពីការប្រមូល និងកត់ត្រាផលចាប់ | ១,៦០០,០០០ | | ២០១៧ | ២០១៩ |
| *៣.២.ការកសាងធនធានមនុស្សទាក់ទងនឹងការបង្កើតមុខរបរ* | | | | | |
| ៣.២.១.បង្កើត និងគាំទ្រក្រុមស្ត្រី | ក្រុមស្ត្រី ត្រូវបានបង្កើត | ៤,០០០,០០០ | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៣.២.២.របៀបកែច្នៃ (ត្រី បង្គាក្រៀម ....) | របៀបកែច្នៃ (ត្រី បង្គាក្រៀម ....) ត្រូវបណ្តុះបណ្តាល | | | ២០១៧ | ២០១៩ |
| *៣.៣.ទស្សនៈកិច្ចសិក្សា* | | | | | |
| ៣.៣.១.របៀបគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលក្នុងសហគមន៍ប្រកបដោយប្រសិទ្ធភាព | | ៤,០០០,០០០ | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៣.៣.២.ការស្វែងរកការគាំទ្រ និងទីផ្សារលក់ផលិតផល | | ៤,០០០,០០០ | | ២០១៧ | ២០១៩ |
| ៤.ការស្វែងរកថវិការដើម្បីគ្រប់គ្រង-អភិរក្សធនធានជលផលឲ្យមាននិរន្តរភាព និងលើកស្ទួយជីវភាពសមាជិកសហគមន៍នេសាទ | | | | | |
| ៤.១.ថ្លៃសមាជិកភាពសហគមន៍នេសាទ | ថ្លៃឈ្នួលត្រូវបានប្រមូលពី សមាជិកភាពសហគមន៍នេសាទ | ២៥០,០០០ | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៤.២.ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទ | ភាគទានប្រចាំឆ្នាំពីសមាជិកសហគមន៍នេសាទត្រូវបានប្រមូល | ១,២៥០,០០០ | | ២០១៧ | ២០១៩ |
| ៤.៣.វិភាគទានប្រចាំឆ្នាំពីសប្បុរសជន | វិភាគទានប្រចាំឆ្នាំពីសប្បុរសជន ត្រូវបានប្រមូល | ១,០០០,០០០ | | ២០១៧ | ២០១៩ |
| ៤.៤.វិភាពទានពីអ្នកនេសាទមិនមែនជាសមាជិក | វិភាពទានពីអ្នកនេសាទមិនមែនជាសមាជិកត្រូវបានប្រមូល | ៩,០០០,០០០ | | ២០១៧ | ២០១៩ |
| ៤.៥.ការអភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ | អភិវឌ្ឍន៍វារីវប្បកម្មក្នុងសហគមន៍នេសាទ ត្រូវបានអនុវត្ត | ៨០,០០០,០០០ | | ២០១៧ | ២០១៩ |
| ៤.៦.ចិញ្ចឹមត្រីក្នុងស្រះ | ស្រះចិញ្ចឹមត្រី ត្រូវបានរៀបចំ | | | ២០១៧ | ២០១៩ |
| ៤.៧.ចិញ្ចឹមត្រីក្នុងថង់ប្លាស្ទិក ឬអាងស៊ីម៉ង់ស៍ | ចិញ្ចឹមត្រីក្នុងថង់ប្លាស្ទិក ឬអាងស៊ីម៉ង់ស៍ | | | ២០១៧ | ២០១៩ |
| ៤.៨.ចិញ្ចឹមគ្រែងឈាម | គ្រែងឈាម ត្រូវបានចិញ្ចឹម | | | ២០១៧ | ២០១៩ |
| ៤.៩.បង្កើត និងគាំទ្រសន្សំប្រាក់ | ក្រុមសន្សំប្រាក់ ត្រូវបានបង្កើត | | | ២០១៧ | ២០១៩ |
| ៤.១០.បង្កើត និងគាំទ្រក្រុមអ្នកផលិត | ក្រុមអ្នកផលិត ត្រូវបានបង្កើត | | | ២០១៧ | ២០១៩ |
| ៤.១១.បង្កើតកន្លែងកំសាន្តសហគមន៍ | កន្លែងកំសាន្តសហគមន៍ ត្រូវបានបង្កើត | | | ២០១៧ | ២០១៩ |
| ៥.ការងារអភិរក្សធនធានជលផល | | | | | |
| ៥.១.ពង្រីកកន្លែងស្តារអភិរក្ស និងកន្លែងអភិរក្សវារីសត្វ | | | | ២០១៧ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| ជលផល | | | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | | |
| ៥.១.១.អភិរក្សជីវៈចម្រុះក្នុងសហគមន៍១០ ហិកតា | ការអភិរក្សជីវៈចម្រុះក្នុងសហគមន៍១០ ហិកតា | ៣៦,000,000 | | ២០១៧ | ២០១៩ |
| ៥.១.២.បង្កើតកន្លែងអភិរក្សបក្សី និងភេ ១០ ហិកតា | កន្លែងអភិរក្សបក្សី និងភេ ១០ ហិកតា ត្រូវបានបង្កើត | ៣៦,000,000 | | ២០១៧ | ២០១៩ |
| ៥.១.៣.បង្កើតកន្លែងអភិរក្សគ្រែងឈាម ២០ ហិកតា | កន្លែងអភិរក្សគ្រែងឈាម ២០ ហិកតា ត្រូវបានបង្កើត | ៣៦,000,000 | | ២០១៧ | ២០១៩ |
| *៥.២.កសាង និងស្តារហេដ្ឋារចនាសម្ព័ន្ធ* | | | | | |
| ៥.២.១.ដាក់លួបង្គោលថ្ម | លួបង្គោលថ្ម ត្រូវបានដាក់ | ៤,000,000 | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៥.២.២.សង់ប៉ុស្ដិ៍យាម | ប៉ុស្តិ៍យាម ត្រូវបានសង់ | ៤,000,000 | | ២០១៧ | ២០១៩ |
| ៥.២.៣.ដាក់ស្លាកសញ្ញា | ស្លាកសញ្ញាត្រូវបានដាក់ | ២,៨00,000 | | ២០១៧ | ២០១៩ |
| ៥.២.៤.បោះបង្គោលអភិរក្ស | បង្គោលអភិរក្ស ត្រូវបានបោះ | ៨,000,000 | | ២០១៧ | ២០១៩ |
| ៥.២.៥.ទិញទូកល្បាត និងសម្ភារៈល្បាត | ទូកល្បាត និងសម្ភារៈល្បាត ត្រូវបានទិញ | ៦,000,000 | | ២០១៧ | ២០១៩ |
| ៥.២.៦.សាងសងប៉មភ្លើងសុវត្ថិភាព | ប៉មភ្លើងសុវត្ថិភាព ត្រូវបានសាងសង | ៤,000,000 | | ២០១៧ | ២០១៩ |
| ៥.២.៧.សម្ភារៈផ្សព្វផ្សាយ | សម្ភារៈផ្សព្វផ្សាយ ត្រូវបានផលិត | ១,៥00,000 | | ២០១៧ | ២០១៩ |
| *៥.៣.បង្កើតថ្នាលផ្សាំនិងបណ្តុះកូនឈើ* | | ៣,២00,000 | | ២០១៧ | ២០១៩ |
| ៦.ការងារកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ | | | | | |
| ៦.១.ចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំ | ប្រជុំជាមួយក្រុមប្រឹក្សាឃុំត្រូវបានចូលរួម | ១,៤៤0,000 | ដៃគូអភិវឌ្ឍ សប្បុរសជន រដ្ឋាភិបាល | ២០១៧ | ២០១៩ |
| ៦.២.ចូលរួមប្រជុំជាមួយជលផល | ប្រជុំជាមួយជលផលត្រូវបានចូលរួម | ១,៤៤0,000 | | ២០១៧ | ២០១៩ |
| ៦.៣.ចូលរួមប្រជុំជាមួយសាលាស្រុក | ប្រជុំជាមួយសាលាស្រុក ត្រូវបានចូលរួម | ១,០៨0,000 | | ២០១៧ | ២០១៩ |
| ៦.៤.ចូលរួមប្រជុំជាមួយសាលាខេត្ត | ប្រជុំជមួយសាលាខេត្តត្រូវបានចូលរួម | ៧២0,000 | | ២០១៧ | ២០១៩ |
| ៦.៧.ចូលរួមប្រជុំជាមួយបរិស្ថាន | ប្រជុំជាមួយបរិស្ថានត្រូវបានចូលរួម | ១២0,000 | | ២០១៧ | ២០១៩ |
| ៦.៨.ចូលរួមទិវាមច្ឆជាតិ | ទិវាមច្ឆជាតិត្រូវបានចូលរួម | | | ២០១៧ | ២០១៩ |

| | | | | | |
|---|---|---|---|---|---|
| | | ១,២០០,០០០ | | | |
| ៦.៩.ចូលរួមជាមួយអង្គការដៃគូ | ប្រជុំជាមួយអង្គការដៃគូត្រូវបានចូលរួម | ២,៤០០,០០០ | | ២០១៧ | ២០១៩ |
| | សរុប | | | | |

## តារាងកម្មវិធីការងារប្រចាំឆ្នាំ ២០១៧-២០១៩

| សកម្មភាព | ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ២០១៧ | | | | | | | | | | | | ២០១៨ | | | | | | | | | | | | ២០១៩ | | | | | | | | | | | |
| | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ |
| ១.ការងារគ្រប់គ្រងធនធានជលផល | | x | x | | | | x | x | | | | | | x | x | | x | | | x | x | | | | | x | x | | x | | | | x | x | | |
| ២.ផែនការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សមាជិកនិងអ្នកខាងក្រៅ | | | x | x | | | | x | x | x | | | | | | x | x | x | x | | | | x | x | x | x | | | | | | x | x | x | x | |
| ៣.ការអភិវឌ្ឍន៍ធនធានមនុស្សក្នុងសហគមន៍នេសាទ | x | x | x | | | x | x | x | x | x | | | | | x | x | x | x | | | | | | | | x | x | x | x | | x | | | | | |
| ៤.ការស្វែងរកថវិការដើម្បីគ្រប់គ្រង-អភិរក្សធនធានជលផលឲ្យមាននិរន្តរភាព និងលើកស្ទួយជីវភាពសមាជិកសហគមន៍នេសាទ | | | x | x | x | x | | x | | | | | x | x | x | x | | x | x | x | | | | | | | x | x | x | x | | x | x | x | | |
| ៥.ការងារអភិរក្សធនធានជលផល | x | x | x | | x | x | x | x | | x | | x | x | x | x | | x | x | | | | | x | x | x | x | | x | x | | | x | x | x | x | |
| ៦.កិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធ | | x | x | x | x | | x | x | x | x | x | x | | x | x | x | x | | x | x | x | x | x | x | x | x | x | | x | x | x | x | | x | x | x |
| | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

សូមគោរពជូន
លោកមេឃុំកណ្តាល
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃព្រហស្បតិ៍៤ កើត ខែបុស្ស ឆ្នាំរការ នព្វស័ក
ព.ស ២៥៦១
ត្រូវ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៧
**ប្រធានគណៈកម្មការសហគមន៍នេសាទ**

លេខ ០៣៦/១៧ភ.កប
បានឃើញ និង គោរពជូន
លោកនាយសង្កាត់រដ្ឋបាលជលផលថ្មស
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃព្រហស្បតិ៍ ៤ កើត ខែបុស្ស ឆ្នាំរការ
នព្វស័ក ព.ស ២៥៦១
ត្រូវ ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៧
**មេឃុំ**

បានឃើញ និង គោរពជូន
លោកនាយផ្នែករដ្ឋបាលជលផលបូទុមសាគរ
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃសុក្រ ៥ កើត ខែបុស្ស ឆ្នាំរការ នព្វស័ក
ព.ស ២៥៦១
ត្រូវ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៧
**នាយសង្កាត់រដ្ឋបាលជលផលថ្មស**

បានឃើញ និង គោរពជូន
លោកនាយខណ្ឌរដ្ឋបាលជលផលកោះកុង
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃសុក្រ ៥ កើត ខែបុស្ស ឆ្នាំរការ នព្វស័ក
ព.ស ២៥៦១
ត្រូវ ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០១៧
**នាយផ្នែករដ្ឋបាលជលផល**
**បូទុមសាគរ**

លេខ : ០០១...
បានឃើញ និងគោរពជូន
លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ខេត្តកោះកុង
ដើម្បីជូនពិនិត្យ និងសម្រួល
ថ្ងៃអង្គារ ១ រោច ខែបុស្ស ឆ្នាំរការ នព្វស័ក ព.ស ២៥៦១
ត្រូវ ថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០១៨
**នាយខណ្ឌរដ្ឋបាលជលផលកោះកុង**

លេខ : ០០៣......
បានឃើញ និង គោរពជូន
ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
ប្រធានរដ្ឋបាលជលផល
ដើម្បីពិនិត្យ និង សម្រេចដោយអនុគ្រោះ
ថ្ងៃ...... ខែ ...... ឆ្នាំរការ នព្វស័ក ព.ស ២៥៦១
ត្រូវ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៨
**ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់**
**និងនេសាទ ខេត្តកោះកុង**

**អ៊ុំ ម៉េងលាង**

លេខ : ៩២០...
បានឃើញ និងឯកភាព
ថ្ងៃ...... ខែ...... ឆ្នាំរការ នព្វស័ក ព.ស ២៥៦១
ត្រូវ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១៨
**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា**
**ប្រធានរដ្ឋបាលជលផល**

**ស្រេង ជាសាន**